ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ១៣១៧/១៩ ក.អ.ជ

ថ្ងៃសុក្រ ៩កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៩

# របាយការណ៍
## វឌ្ឍនភាពការងារប្រចាំខែកក្កដា ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

### I. សេចក្តីផ្តើម

ឈានចូលដល់ខែកក្កដា ឆ្នាំ២០១៩ នេះ ការអនុវត្តផែនការសកម្មភាពកាន់តែមមាញឹកយ៉ាងសកម្ម ដែលកំពុងជះឥទ្ធិពលលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកាន់តែលេចធ្លោឡើងបង្ហាញយ៉ាងច្បាស់ពីការផ្សារភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សេវាសាធារណៈផ្សេងៗ ទៅនឹងស្ថានភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅជនបទ ។ ជាទិដ្ឋភាពរួមយើងសង្កេតឃើញប្រជាជនកំពុងរស់នៅយ៉ាងសុខក្សេមក្សាន្តក្នុងសង្គមគ្រួសារនីមួយៗដោយគ្មានបារម្ភភ័យខ្លាចអសន្តិសុខអ្វីទាំងអស់ ។ ការផ្លាស់ប្តូរស្ថានភាពរស់នៅកាន់តែស៊ីវិល័យជាងមុនតាមរយៈការប្រើប្រាស់សម្ភារៈប្រចាំថ្ងៃក្នុងលំនៅឋាន តាមគ្រួសារមួយភាគធំដូចជា ទូរទស្សន៍ ម៉ូតូ ទូរស័ព្ទដៃ អគ្គិសនី បង្គន់អនាម័យ អណ្តូងទឹកស្អាត ឬបណ្តាញទឹកតាមប្រព័ន្ធទឹកស្អាត ។ល។ សុខភាពផ្លូវកាយ និងផ្លូវចិត្តកាន់តែរឹងមាំជាងមុន ។ ក្នុងគោលដៅបង្កើនប្រាក់ចំណូលតាមគ្រួសារនីមួយៗនៅជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវកម្មវិធីនយោបាយមួយសមស្របនឹងនិន្នាការ រីកចំរើននាពេលបច្ចុប្បន្ន ដើម្បីជានាលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជននៅជនបទឲ្យកាន់តែល្អប្រសើរឡើងថែមទៀតទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅជនបទ។ ក្នុងខែកក្កដា ឆ្នាំ២០១៩ នេះក្រសួងសម្រេចបានដូចខាងក្រោម៖

### II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

#### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែកក្កដា ឆ្នាំ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៧៩៩ នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែមិថុនា ឆ្នាំ២០១៩ មានការថយចុះចំនួន ០៥ នាក់ ដោយការចូលនិវត្តន៍ ។ ក្រសួងបានទទួលលិខិតចូលចំនួន ១៨៩ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ២៣៩ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ០៤០ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២៣៩ច្បាប់ ។

#### ២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងខែកក្កដា ឆ្នាំ ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិ សរុបចំនួន ១៧ ករណី ដែលក្នុងនោះបានដោះស្រាយ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

ជូនប្រជាពលរដ្ឋបានចំនួន ០៧ ករណី ។

៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែកក្កដា នេះ ក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៦ ២៨៦ ៥១៨ ០៥០ រៀល ស្មើនឹង ៤,៨០% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ១២ ២០៧ ២២០ ០០០ រៀល ស្មើនឹង ៦,៤២% នៃច្បាប់ថវិកា ។

៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- រៀបចំឯកសារ និងចូលរួមការពារកញ្ចប់ថវិកាឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទនៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីភាព **ឯកឧត្តម ហ្វត សារឹម** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ និង **ឯកឧត្តម អ៊ុច លុយណា** អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បន្តពិនិត្យ និងកែសម្រួលផែនការថវិកាប្រចាំឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទដើម្បី ត្រៀមចរចារថវិកាកម្រិតគោលនយោបាយ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលាស្តីពី KoRAA High Level Workshop-2019 ដែលរៀបចំដោយនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្មនៃប្រទេសស្រីលង្កា និងសហការជាមួយរដ្ឋបាលអភិវឌ្ឍន៍ជនបទកូរ៉េ (RDA) នៅទីក្រុងកូឡំបូ ប្រទេសស្រីលង្កា
- ចូលរួមកិច្ចប្រជុំ Public Investment Management Assessment (PIMA ) របស់ក្រុមការងារស្រាវជ្រាវ និងវាយតម្លៃការចំណាយហិរញ្ញវត្ថុសាធារណៈ និងបំណុល ក្រោមអធិបតីភាព **ឯកឧត្តម ចាន់ សុធី** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារ Raffles Hotel Le Royal រាជធានីភ្នំពេញ
- ចុះត្រួតពិនិត្យការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តប៉ៃលិន និងកោះកុង
- ចុះពិនិត្យការអនុវត្តផែនការឆ្នាំ ២០១៩ និងណែនាំការរៀបចំផែនការកម្មវិធីឆ្នាំ ២០២០ របស់មន្ទីរ នៅខេត្តកំពត កោះកុង និងកំពង់ចាម
- ចូលរួមកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេសដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងសូចនករសមិទ្ធកម្មគន្លឹះសម្រាប់តាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស លើគម្រោងផែនការចំណូល-ចំណាយថវិកាឆ្នាំ ២០២០ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់សំណើសុំបន្តកិច្ចព្រមព្រៀង សហប្រតិបត្តិការ និងចុះហត្ថលេខារវាងក្រសួង

អភិវឌ្ឍន៍ជនបទ និងអង្គការ ចំនួន ០៤ រួមមាន អង្គការ Lifewater អង្គការ Save the Chidren អង្គការ ការីតាសកម្ពុជា និងអង្គការ អភិវឌ្ឍធនធានអន្តរជាតិ

- បានផ្តល់សំណើសុំហត្ថលេខា លើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាមួយ អង្គការអេស៊ាន អោថរីថ្ង និងអង្គការ អាគ្រីស៊ុតអន្តរជាតិ
- បានផ្តល់សំណើសុំអន្តរាគមន៍ដើម្បីចុះបញ្ជីសុំស្លាកលេខ ONG សម្រាប់ទោចក្រយានយន្ត ០៦គ្រឿង របស់អង្គការសាម៉ារីតាន់ភឺស រថយន្ត០១គ្រឿង និងទោចក្រយានយន្ត ០២គ្រឿង របស់អង្គការ Good Neighbor Cambodia
- បានផ្តល់សំណើសុំអន្តរាគមន៍ដើម្បីលើកលែងពន្ធនាំចូលបន្ទះសូឡា របស់អង្គការ ជីវិតថ្លៃថ្នូរ និងការលើកលែងពន្ធនាំចូលសម្ភារបច្ចេកទេស របស់អង្គការ អាក់សិនអេត
- ចុះពិនិត្យការងាររបស់អង្គការក្រៅរដ្ឋាភិបាលនៅខេត្តមណ្ឌលគិរី និងស្ទឹងត្រែង ។

៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំកិច្ចប្រជុំ ស្តីពីការពិនិត្យលើគ្រោងថវិកាកម្មវិធីឆ្នាំ២០២០ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០២ គឺ ខេត្តប៉ៃលិន និងកំពង់ឆ្នាំង
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីប្រព័ន្ធ FMIS ដល់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ នៅខេត្តបាត់ដំបង
- រៀបចំបូកសរុបរបាយការណ៍ត្រីមាសទី២ របស់ក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំផែនការចំណាយរបស់ដៃគូសម្រាប់ថវិកាឆ្នាំ២០២០ របស់ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ ។

៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៨ - ២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន០៧ រួមមាន ខេត្តកណ្តាល កំពង់ស្ពឺ កំពត កែប តាកែវ ក្រចេះ និងស្ទឹងត្រែង
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "Technical Orientation to Public Sector Internal Auditors សម្រាប់ការអនុវត្តគម្រោងគ្រប់គ្រងគ្រោះមហន្តរាយកម្ពុជា និងអាស៊ីអាគ្នេយ៍ នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ ។

## III. សកម្មភាពការងារជំនាញ

### ១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ

- គម្រោងស្ថាបនា កែលម្អផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៩ មាន៩១ គម្រោងកំពុងដំណើរការការដ្ឋានបានចំនួន ៧៧គម្រោង លទ្ធផលគិតជាមធ្យម ៤៧.២៥ %
- ការងារថែទាំផ្លូវលក្ខណៈខួប ឆ្នាំ២០១៩ មាន ចំនួន ២៨ គម្រោង ស្មើនឹង ៦៣ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ៥៥.១១ %
- ការងារថែទាំផ្លូវលក្ខណៈប្រចាំ ឆ្នាំ២០១៩ មានចំនួន ៤០ គម្រោង ស្មើនឹង ៣៦៩ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ១៧.៤៨ %
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាព ១៦គម្រោង អនុវត្តដោយនាយកដ្ឋានស្ថាបនា និងវិស្វកម្ម ក្រសួងមហាផ្ទៃ នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ បញ្ជាការដ្ឋានវិស្វកម្មកងទ័ពជើងគោក ក្រុមហ៊ុន ប៊ិន បូរីបុត្រ (ប៊ីប៊ីប៊ីស៊ី) ខូអិលធីឌី និងក្រុមហ៊ុន ម៉ុង ឬទ្ធី លើការងារស្ថាបនា
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចរចាថ្លៃបានចំនួន ១៣គម្រោង អនុវត្តដោយបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ និងនាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការថែទាំផ្លូវជនបទ និង វគ្គ Baseline Survey and GIS នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី "ការរៀបចំកំណត់ និងបែងចែកតំបន់គ្រប់គ្រង នៅដែនជម្រកសត្វព្រៃសៀមប៉ាង និងសៀមប៉ាងខាងលិច" ភូមិសាស្ត្រខេត្តស្ទឹងត្រែង នៅក្រសួងបរិស្ថាន ។

### ២. ការងារផ្គត់ផ្គង់ទឹកជនបទ

- ដឹកនាំក្រុមការងារខួងអណ្តូងចំនួន ០៣អណ្តូង នៅឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល
- ចុះត្រួតពិនិត្យ និងវាយតម្លៃសំណង់អណ្តូងស្នប់ចំនួន ០៤ (១០០%) នៅខេត្តកណ្តាល
- ចុះត្រួតពិនិត្យ វាយតម្លៃអណ្តូង ចុះសិក្សាទីតាំងសាងសង់អណ្តូងស្នប់ និងចុះសិក្សាទីតាំងសាងសង់ប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចសហគមន៍ នៅខេត្តមណ្ឌលគិរី ក្រចេះ ឧត្តរមានជ័យ និងព្រះវិហារ
- ដឹកនាំកិច្ចប្រជុំពិភាក្សាអំពីការអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជំហាន ២ (ហិរញ្ញប្បទានបន្ថែម) ការរៀបចំ និងការពង្រឹងការងារលើគម្រោងជំហាន ៣ របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០៣ រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង
- ចូលរួមកិច្ចប្រជុំលើកទី ៣១ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

៣. ការងារថែទាំសុខភាព និងអនាម័យជនបទ

- សាងសង់បង្គន់ អនាម័យឯកជន ចាក់ទឹក បានចំនួន ១៧០បង្គន់ នៅខេត្តបន្ទាយមានជ័យ និងស្វាយរៀង
- រៀបចំកិច្ចប្រជុំលើកទី៣១ របស់ក្រុមការងារបច្ចេកទេស PWG-RWSSH ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានក្រុមការងារ PWG-RWSSH ដែលមានអ្នកចូលរួមសរុបចំនួន ៣៦នាក់
- ចុះត្រួតពិនិត្យការផលិតសម្ភារៈបង្គន់អនាម័យ និងជំរុញសហគមន៍ជីករណ្តៅសម្រាប់សាងសង់បង្គន់អនាម័យនៅក្នុងខេត្តគោលដៅចំនួន១២ រួមមាន ខេត្តត្បូងឃ្មុំ កំពង់ចាម កំពង់ឆ្នាំង ក្រចេះ សៀមរាប កំពង់ស្ពឺ ព្រះសីហនុ កោះកុង កែប ស្វាយរៀង ឧត្តរមានជ័យ និងប៉ៃលិន
- រៀបចំកិច្ចប្រជុំលេខាធិការដ្ឋានក្រុមការងារទឹកស្អាត និងអនាម័យ ដើម្បីរៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេសទឹកស្អាត និងអនាម័យក្រោមអធិបតីភាព **ឯកឧត្តម ជ្រាយ ម៉ុម** អគ្គនាយកបច្ចេកទេស នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះត្រួតពិនិត្យតាមដាន និងបំផុសការលើកកម្ពស់អនាម័យតាមសហគមន៍ចំនួន ០៥ នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលមានប្រជាជនចូលរួមសរុបចំនួន ១៩៧នាក់ ស្រីចំនួន ៦៧នាក់
- សហការរៀបចំក្រុមដើម្បីផ្ទៀងផ្ទាត់ស្រុករំដួលជាស្រុក ODF ជាលទ្ធផលបានបង្ហាញថាស្រុករំដួលបានសម្រេចជាស្រុក ODF
- ចូលរួមពិធីប្រកាសជាផ្លូវការ ការដាក់ឲ្យអនុវត្តន៍គម្រោងអាហារូបត្ថម្ភនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា រាជធានីភ្នំពេញ ។

៤. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះពិនិត្យតាមដានការធ្វើបច្ចុប្បន្នភាព និងពិភាក្សាការងារពង្រឹងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តកំពង់ឆ្នាំង និងសៀមរាប
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកំពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ នៅខេត្តកំពង់ស្ពឺ
- រៀបចំផែនការបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ជំហានទី២ ឆ្នាំ ២០១៩
- បូកសរុបទិន្នន័យការធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ប្រចាំខែកក្កដា ឆ្នាំ ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្នុងវគ្គទី ២ ឆមាសទី២ ឆ្នាំ ២០១៩ ចំនួន ០៤ មុខជំនាញ សរុបសិក្ខាកាមជ្រើសរើសបានចំនួន ១៣២ នាក់

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនៅក្នុងមជ្ឈមណ្ឌល និងក្រៅមជ្ឈមណ្ឌល ចំនួន ២៩ វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៦០០ នាក់ ។

៥. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ២២៨នាក់ ក្នុងនោះស្រីចំនួន ៤២នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៦៥នាក់ ក្នុងនោះស្រីចំនួន ១២នាក់
- មន្ត្រីចូលរួមទស្សនកិច្ចសិក្សាក្រៅប្រទេស ចំនួន ០១នាក់ ក្នុងនោះស្រីចំនួន ០០នាក់
- បានរៀបចំឯកសារ ចាត់បញ្ជូនមន្ត្រី ចូលរួមវគ្គបណ្តុះបណ្តាល ចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងប្រកួតប្រជែង ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត និងវគ្គបណ្តុះបណ្តាលភាសាអង់គ្លេស ក្រៅប្រទេស និងក្នុងប្រទេស ជូនមន្ត្រី ចំនួន ២៣នាក់
- រៀបចំសិក្ខាសាលាស្តីពីការចែករំលែកចំណេះដឹងដែលទទួលបានការសិក្សាពីក្រៅប្រទេស ដែលមានសិក្ខាកាមចូលរួមចំនួន ៥៨នាក់ស្ត្រី ០៩នាក់
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលមានសិក្ខាកាមចូលរួមចំនួន ៦៧នាក់ ស្ត្រី ១១នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបញ្ចប់វគ្គបណ្តុះបណ្តាលឆមាសទី ១ និងចុះធ្វើការផ្សព្វផ្សាយនៅតាមតំបន់គោលដៅចំនួន ០៣ ស្រុក ព្រមទាំងបានធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាម សម្រាប់ឆមាសទី ២ ឆ្នាំ ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៩៦នាក់ ស្រី ៧២នាក់ លើ ០៤ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបន្តដំណើរការបណ្តុះបណ្តាល សម្រាប់ឆមាសទី ១ និងបើកវគ្គទី ២ បន្ថែមសម្រាប់ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៣៧នាក់ ស្រី ១១ នាក់ លើ ០៤ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបញ្ចប់វគ្គបណ្តុះបណ្តាលឆមាសទី ១ និងចុះធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាម សម្រាប់ឆមាសទី ២ ឆ្នាំ ២០១៩ នៅតាមតំបន់គោលដៅនៅក្នុងឃុំព្រៃតូច និងឃុំកកោះ ស្រុកមោងឫស្សី
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនបន្ថែម សរុបចំនួន ១២០នាក់ ស្រី ៨២នាក់ លើ ០៤ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តដំណើរការបណ្តុះបណ្តាលរយៈពេលវែង និងបានបើកវគ្គរយៈពេលខ្លី សម្រាប់ឆមាសទី ១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៩នាក់ ស្រី ៣៧នាក់ លើ ០៣ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានបន្តចុះផ្សព្វផ្សាយ និងជ្រើសរើសទីតាំងសម្រាប់គម្រោងបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី លើ០២ មុខជំនាញ សម្រាប់គម្រោងបើកវគ្គបណ្តុះបណ្តាល រយៈពេលខ្លីនាពេលខាងមុខ

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី ១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤១នាក់ ស្រី ១៨នាក់ លើមុខវិជ្ជាកាសាអង់គ្លេស
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បន្តរៀបចំផែនការ និងស្រង់ទិន្នន័យអ្នកមានបំណងចូលរៀនព្រមទាំងបន្តការផ្សព្វផ្សាយពីគម្រោងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនាពេលខាងមុខ ។

៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៤ ១៤៣ ១៤៥ ២៣៥ រៀល (បួនពាន់មួយរយសែសិបបីលានមួយរយសែសិបប្រាំពាន់ពីរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៥៥ ០១២,២៧ ដុល្លារអាមេរិក (មួយលានហាសិបប្រាំពាន់ដប់ពីរដុល្លារ និងម្ភៃប្រាំពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ៣៧៥ នាក់ នៅភូមិ គោលដៅចំនួន ២២៧ ភូមិ ៩៨ឃុំ ៣២ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- ធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែក បច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦ នាក់ ស្រី ៦៤ នាក់ នៅខេត្តស្វាយរៀង
- ចុះតាមដានសកម្មភាពសិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាលគំនិតផ្តួចផ្តើមបង្កើតអាជីវកម្មខ្នាតតូច និងបច្ចេកទេសផលិតសាប៊ូលាងចាន នៅខេត្តស្ទឹងត្រែង
- ចូលរួមវេទិកាអាស៊ាន ចិន លើកទី ១៣ ស្តីពីការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រ និងកិច្ចប្រជុំពាក់ព័ន្ធមួយចំនួន នៅទីក្រុងណាននីង សាធារណរដ្ឋប្រជាមានិតចិន ។

៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ចូលរួមកិច្ចប្រជុំស្តីពី ការចាប់ផ្តើមដំណើរការអនុវត្តគម្រោង "ពិពិធកម្មវិស័យកសិកម្មកម្ពុជា" ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ចាន់ ដារ៉ុង** រដ្ឋលេខាធិការ និងជាប្រធានសម្របសម្រួលគម្រោងនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមជាគណៈអធិបតី និងសម្របសម្រួលក្នុងពិធីអបអរសាទរប្រគល់ប័ណ្ណ ស្តីពី ការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី
- ចូលរួមជាវាគ្មិនកិត្តិយស ក្នុងកម្មវិធីតុមូលស្តីពី "ដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធសមូហភាព"
- ទំនាក់ទំនងជាមួយអង្គការដៃគូ និងក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចតាមបណ្តាខេត្តទាំង ១៥ ។

៨. ការងារយេនឌ័រ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារការប៉ាន់ប្រមាណ យេនឌ័រនៅកម្ពុជា(២០១៩-២០២៣) នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ជំពូក ក្រុមស្រី និងក្មេងស្រីងាយរងគ្រោះ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាបញ្ចប់គម្រោងស្តីពី ការពង្រឹងសមត្ថភាពស្ត្រីសម្រាប់ភាពធន់ទៅនឹងអាកាសធាតុនៅកម្ពុជា នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ។

៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- រៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពី ការកែសម្រួលសមាសភាពក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ និងសមាសភាពលេខាធិការដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

## IV. **ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ**

១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ ខែកក្កដានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៥១,១២%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៦២,៩៨%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៤៩,៩៨%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៥៧,៥៨%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៣៨,៧%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ១០០%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ១០០%

- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ១០០%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ១០០% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ។ គិតត្រឹមដំណាច់ ខែកក្កដានេះ គម្រោងសម្រេចបាន ៖

- ស្រុកមង្គលបុរី : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ខ្សែ មានប្រវែងសរុប ២៧,២០ គ.ម សម្រេចបាន ៤0%
- ស្រុកអូរជ្រៅ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០១ខ្សែ មានប្រវែងសរុប ២០ គ.ម សម្រេចបាន ៤០% ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទ ដោយត្រូវអនុវត្តជា ២ជំហាន ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្ដាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គិតត្រឹមខែកក្កដានេះ គម្រោងដែលបានស្នើសុំក្រាលគ្រួសក្រហមចំនួន ១៤១គម្រោង បាននិងកំពុងអនុវត្តការងារ បានចំនួន ១៣៦គម្រោង ប្រវែងសរុប ៥៤៥ ១៧៧ម៉ែត្រ ដោយឡែកសម្រាប់ជំហាន ២ គម្រោង បាននិងកំពុងអនុវត្តចំនួន ១៦០គម្រោង ប្រវែង ១៦១ ៤០៦ម៉ែត្រ ។

**៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សាងសង់ថ្នាលហាលលាមក សម្រេចបាន ១០០% និងសាងសង់បង្គន់តាមគ្រួសារ (ABC) សម្រេចបាន ០៥% នៅខេត្តបន្ទាយមានជ័យ
- ចុះត្រួតពិនិត្យតាមដានដំណើរការប្រព័ន្ធចែកចាយទឹកខ្នាតតូច នៅខេត្តបន្ទាយមានជ័យ
- សាងសង់បង្គន់តាមគ្រួសារ (ABC) ចំនួន ១៧១ បង្គន់ ជូនប្រជាពលរដ្ឋ បានចំនួន ១២៦ គ្រួសារ និងចាក់កងលូ ជូនប្រជាពលរដ្ឋ បានចំនួន ១០៣ គ្រួសារ នៅខេត្តកំពង់ធំ ។

## V. សេចក្តីសន្និដ្ឋាន

កម្រិតជីវភាពរបស់ប្រជាជននៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា កំពុងប្រែប្រួលកាន់តែល្អប្រសើរជាងមុន ដោយសាររាជរដ្ឋាភិបាលបានផ្តល់សេវាសាធារណៈកាន់តែសម្បូរបែបជាងមុន ដូចជាផ្លូវថ្នល់ចាក់កៅស៊ូកាន់តែច្រើនឡើងៗរហូតដល់ភូមិឋានអ្នកស្រុក សាលារៀន មណ្ឌលសុខភាព អណ្តូងទឹក ស្រះទឹក បណ្តាញទឹកស្អាត បង្គន់អនាម័យ អគ្គិសនី ពីមួយឆ្នាំទៅមួយឆ្នាំ ។ ប្រាក់ចំណូល

របស់ប្រជាពលរដ្ឋក៏មានការកើនឡើងជាលំដាប់ ដោយសាររាជរដ្ឋាភិបាលមានគោលនយោបាយ លើកទឹកចិត្តដល់អ្នកវិនិយោគទុនដើម្បីបង្កើតរោងចក្រ បង្កើតការងារជូនអ្នកស្រុក ។ ទន្ទឹមនឹងនេះដែរក្រសួងអភិវឌ្ឍន៍ជនបទមានកម្មវិធីបណ្តុះបណ្តាលបង្កើតការងារជូនអ្នកស្រុក បង្កើនជំនាញបន្ថែមទៀត ដើម្បីផ្តល់ឱកាសរកប្រាក់ចំណូលបន្ថែមក្រៅពីការងារកសិកម្មដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរលក្ខខណ្ឌរស់នៅរបស់ប្រជាជនបានល្អប្រសើរ ជានាឲ្យបាននូវគុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូប ៕

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**